**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់ អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១២

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 08-Feb-2012, 08:27
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបរបស់ អៀង សារី ទៅនឹងការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសារទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបដិសេធសំណើរបស់គាត់ សុំឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់មន្ត្រីច្បាប់ជាន់ខ្ពស់របស់ខ្លួនប្រាស្រ័យទាក់ទងដោយចំហ និងដោយតម្លាភាពជាមួយភាគីទាំងអស់**

---

ដាក់ដោយ៖

**សហមេធាវីរបស់លោក អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

ផ្ញើជូន៖

**អង្គជំនុំជម្រះតុលាការកំពូល**

ឯកឧត្តម គង់ ស្រីម

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម យ៉ា ណារិន

ចៅក្រម Mottoo NOGUCHI

ចៅក្រម Agnieszka KLONOWIECKA-MILART

ចៅក្រម Chandra NIHAL JAYASINGHE

ផ្ញើជូន៖

**អង្គជំនុំជម្រះតុលាការកំពូល**

ចៅក្រមបម្រុង ស៊ិន រិទ្ធ

ចៅក្រមបម្រុង Florence MUMBA

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមការពារក្តីទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") ឥឡូវនេះសូមឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា[1]ទៅនឹងបណ្តឹងសារទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបដិសេធសំណើរបស់គាត់សុំឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់មន្ត្រីច្បាប់ជាន់ខ្ពស់របស់ខ្លួនប្រាស្រ័យទាក់ទងដោយចំហ និងដោយតម្លាភាពជាមួយភាគីទាំងអស់[2] ។ សហព្រះរាជអាជ្ញាអះអាងថា បណ្តឹងសារទុក្ខនេះមិនអាចទទួលយកបានឡើយដោយសារគ្មានមូលដ្ឋានច្បាប់នៅក្រោមវិធាន១០៤ ឬវិធាន២១ ។ ចម្លើយតបនេះត្រូវធ្វើឡើងជាចាំបាច់ពីព្រោះសហព្រះរាជអាជ្ញាបកស្រាយខុសលើភាពអាចទទួលយកបាននៃបណ្តឹងសារទុក្ខនេះក្រោមវិធាន ១០៤ និងបកស្រាយខុសលើការអនុវត្តត្រឹមត្រូវនៃវិធាន ២១ ។ ចម្លើយតបនេះកម្រិតត្រឹមតែបញ្ហានៃភាពអាចទទួលយកបាន ហើយដូច្នេះ វាមិនត្រូវប៉ះពាល់ដល់សំណើរបស់មេធាវីការពារក្តី សុំឲ្យមានសវនាការដេញដោលផ្ទាល់មាត់ជាសាធារណៈលើខ្លឹមសារនៃបណ្តឹងសារទុក្ខឡើយ ។

## I. ចម្លើយតប

### ក. ចម្លើយតបនេះអាចទទួលយកបានដោយអនុលោមតាមវិធាន ១០៤

១. នៅកថាខណ្ឌទី៣ដល់កថាខណ្ឌទី៥ នៃចម្លើយតបរបស់សហព្រះរាជអាជ្ញាអះអាងថា មេធាវីការពារក្តីលើកអំណះអំណាងថា បណ្តឹងសារទុក្ខនេះអាចទទួលយកបានក្រោមវិធាន១០៤(១) ហើយថាមេធាវីការពារក្តី "យល់ច្រឡំដោយចេតនា" ក្នុងការអានវិធាន១០៤ ពីព្រោះមានតែវិធាន១០៤(៤) ទេ ដោះស្រាយជាមួយបណ្តឹងសារទុក្ខភ្លាមៗ។ តាមពិតមេធាវីការពារក្តីមិនបានយល់ច្រឡំក្នុងការអានវិធាន ១០៤ នោះទេ ។ វិធាន ១០៤(១) ចែងថា "អង្គជំនុំជម្រះតុលាការកំពូល*ត្រូវសម្រេចលើ* បណ្តឹងសាទុក្ខជំទាស់ទៅនឹងសាលក្រមលើអង្គសេចក្តី ឬសេចក្តីសម្រេចនៃអង្គជំនុំជម្រះសាលាដំបូងដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម ក)កំហុសលើអង្គច្បាប់ដែលនាំឲ្យ

---

[1] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសារទុក្ខប្រឆាំងនឹងសេចកក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបដិសេធសំណើរបស់គាត់ សុំឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់មន្ត្រីច្បាប់ជាន់ខ្ពស់របស់ខ្លួនការប្រាស្រ័យទាក់ទងដោយចំហ និងដោយតម្លាភាពជាមួយភាគីទាំងអស់ ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១២ E154/1/1/2 ("ចម្លើយតប") ។

[2] បណ្តឹងសារទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបដិសេធ សំណើរបស់គាត់សុំឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់មន្ត្រីច្បាប់ជាន់ខ្ពស់របស់ខ្លួនប្រាស្រ័យទាក់ទងដោយចំហ និងតម្លាភាពជាមួយភាគីទាំងអស់ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១២ E154/1/1/1 ("បណ្តឹងសារទុក្ខ") ។

មោឃៈភាពសាលក្រមលើអង្គសេចក្តី ឬសេចក្តីសម្រេចនោះ ឬខ)កំហុសនៃអង្គហេតុដែលនាំអោយសាលក្រមលើអង្គសេចក្តី ឬ សេចក្តីសម្រេចនោះមានភាពមិនយុត្តិធម៌"[3]។ អាស្រ័យហេតុនេះមេធាវីការពារក្តីចាំបាច់ពន្យល់អំពីកំហុសលើអង្គច្បាប់ និងកំហុសលើអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូង។ វាក៏ជាការចាំបាច់ផងដែរនៅករណី ដែលអង្គជំនុំជម្រះតុលាការកំពូលសម្រេចថា វិធាន ២១ តម្រូវឲ្យអង្គជំនុំជម្រះតុលាការកំពូលទទួលយកបណ្តឹងសារទុក្ខនេះតាមរយៈការបកស្រាយវិធាន ១០៤ក្នុងន័យទូលាយ ឬតាមរយៈការទទួលយកបណ្តឹងសារទុក្ខនេះដោយផ្ទាល់ក្រោមវិធាន ២១ ។

២. សហព្រះរាជអាជ្ញាអះអាងនៅក្នុងកថាខណ្ឌទី៧ថាសេចក្តីសម្រេចដែលរងការជំទាស់នេះ[4] មិនមែនជា "សេចក្តីសម្រេចស្តីពីការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការក្រោមវិធាន៣៥(៦)ឡើយ" ដោយសារតែសេចក្តីសម្រេចដែលរងការជំទាស់នេះមិនបានយោង ឬទាក់ទងគ្នាបែបណាមួយទៅនឹងការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការ ដូចដែលមាននៅក្នុងខ្លឹមសារនៃវិធាន ៣៥ ទេ ។ នេះគឺជាការបកស្រាយមិនត្រឹមត្រូវនៃវិធាន ១០៤(៤)(ឃ)។ មិនមានលក្ខខណ្ឌតម្រូវថាសេចក្តីសម្រេចមួយយោងខ្លួនឯងថាជា "សេចក្តីសម្រេចស្តីពីការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការ" ដើម្បីធ្វើឲ្យសេចក្តីសម្រេចនោះ ក្លាយជាសេចក្តីសម្រេចស្តីពីការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការឡើយ ។ សេចក្តីសម្រេចដែលរងការជំទាស់នេះ គឺជាសេចក្តីសម្រេចស្តីពីការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការ ដូច្នេះមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងជំនួសមុខឲ្យអង្គជំនុំជម្រះសាលាដំបូង បានជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតុលាការតាមរយៈការប្រាស្រ័យទាក់ទងតែជាមួយភាគីមួយចំនួន អំពីបញ្ហាសំខាន់ៗនៃការគ្រប់គ្រងសវនាការ ដែលប៉ះពាល់ដល់ភាគីផ្សេងទៀត ។ តាមរយៈសេចក្តីសម្រេចដែលរងការជំទាស់នេះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ការប្រព្រឹត្តបែបនេះអាចទទួលយកបាន ហើយដូច្នេះវាមិនមែនជាការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតុលាការឡើយ។ ម្យ៉ាងទៀតសេចក្តីសម្រេចដែលរងការជំទាស់ខ្លួនឯង គឺជាការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការ ដោយសារតែសេចក្តី

---

[3] បញ្ជាក់បន្ថែម ។

[4] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា "អៀង សារី ស្នើឲ្យអង្គជំនុំជម្រះបង្គាប់មន្ត្រីជាន់ខ្ពស់ប្រាស្រ័យទាក់ទងដោយចំហ និងដោយតម្លាភាពជាមួយភាគីទាំងអស់ ទាក់ទងនឹងការគ្រប់គ្រងសវនាការ (E154) ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១១, E154/1 (សេចក្តីសម្រេចដែលរងការជំទាស់") ។

សម្រេចនេះ អន់អោនដល់ការប្រព្រឹត្តបែបនេះ និងបានអនុញ្ញាតដោយស្ងៀមស្ងាត់ឲ្យបន្តមានការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការតទៅទៀត ។ អង្គជំនុំជម្រះតុលាការកំពូលមានយុត្តាធិការដោះស្រាយការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការ អនុលោមតាមវិធាន ១០៤(៤)(ឃ) និងវិធាន ៣៥ ។

៣. សហព្រះរាជអាជ្ញាអះអាងនៅក្នុងកថាខណ្ឌទី៧ថា ការសំអាងហេតុថាបណ្តឹងសារទុក្ខអាចទទួលយកបានក្រោមវិធាន ១០៤(៤)(ឃ) នឹងបើកចំហឲ្យមានការប្តឹងសារទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចណាមួយរបស់អង្គជំនុំជម្រះសាលាដំបូង ដោយអះអាងថាបើសិនបណ្តឹងសារទុក្ខនេះត្រូវបានទទួលយលក្រោមវិធាន ១០៤(៤)(ឃ) "ភាគីណាមួយអាចនឹងដាក់បណ្តឹងសារទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេច*ណាមួយ*របស់អង្គជំនុំជម្រះសាលាដំបូង ដោយគ្រាន់តែចោទប្រកាន់ថាសេចក្តីសម្រេចនោះបានជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការ"[5] ។ បញ្ហាមិននៅត្រង់ថាតើបណ្តឹងសារទុក្ខដទៃទៀតអាចត្រូវបានគេទទួលយក បើសិនបណ្តឹងសារទុក្ខនេះត្រូវបានទទួលយកទេនោះ។ បញ្ហានៅទីនេះ គឺថាតើបណ្តឹងសារទុក្ខនេះទទួលយកបានក្រោមវិធានផ្ទៃក្នុងដែរ ឬអត់នោះ ។ បើគ្រាន់តែមានការចោទប្រកាន់ដ៏សាមញ្ញថាសេចក្តីសម្រេចនោះបានជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការប៉ុណ្ណឹង វានឹងមិនគ្រប់គ្រាន់ដើម្បីតម្រូវឲ្យអង្គជំនុំជម្រះតុលាការកំពូលទទួលយកបណ្តឹងសារទុក្ខណាមួយឡើយ។

៤. សហព្រះរាជអាជ្ញាបានអះអាងក្នុងកថាខណ្ឌទី៨ ថាបណ្តឹងសាទុក្ខនេះ "មិនអើពើនឹងស្មារតីនិងអត្ថន័យនៃសេចក្តីសម្រេចយ៉ាងច្បាស់របស់អង្គជំនុំជម្រះចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១២ ដែលក្នុងនោះបានសម្រេចថា ទាំងកំហុសខាងអង្គច្បាប់ណាមួយក្តី ឬទាំងការរំលោភលើឆន្ទានុសិទ្ធិពីសំណាក់អង្គជំនុំជម្រះសាលាដំបូងក្តី គឺសុទ្ធតែមិនបង្កើតបានដោយផ្ទាល់ទៅជាការជ្រៀតជ្រែកចូលទៅក្នុងកិច្ចការរដ្ឋបាលតុលាការដោយបានដឹងជាមុន និងដោយចេតនាតាមអត្ថន័យដូចដែលបានចែងក្នុងវិធាន៣៥ នៃវិធានផ្ទៃក្នុង"[6] នោះឡើយ ។ បញ្ហានេះជារឿងមិនត្រឹមត្រូវទេ ។ អង្គជំនុំជម្រះតុលាការកំពូលលើកឡើងថាកំហុសខាងអង្គច្បាប់ ឬការរំលោភឆន្ទានុសិទ្ធិមិនអាចបង្កើតបាន

---

[5] បញ្ជាក់បន្ថែមនៅក្នុងសារណាដើម ។

[6] ដកស្រង់សេចក្តីសម្រេចលើបណ្តឹងសារទុក្ខរបស់ អៀង សារី ប្រឆាំងនឹងដីការបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឲ្យជនជាប់ចោទមានវត្តមានក្នុងសាលសវនា, ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១២, ឯកសារ E130/4/3, ទំព័រទី២។

*ដោយផ្ទាល់* ជាការជ្រៀតជ្រែកដោយចេតនា និងដោយដឹងជាមុនចូលទៅក្នុងកិច្ចការរដ្ឋបាលតុលាការឡើយ ។ ដូចដែលបានពន្យល់នៅក្នុងបណ្តឹងសារទុក្ខនេះរួចហើយ អង្គជំនុំជម្រះសាលាដំបូងមិនត្រឹមតែមានកំហុសអង្គច្បាប់ ឬរំលោភឆន្ទានុសិទ្ធិរបស់ខ្លួនប៉ុណ្ណោះទេ ។ អង្គជំនុំជម្រះសាលាដំបូងពិតជាបានណែនាំមន្ត្រីច្បាប់ជាន់ខ្ពស់របស់ខ្លួនឲ្យធ្វើការប្រាស្រ័យទាក់ទងគ្នា *រវាងភាគីតែម្ខាង* (ហើយថែមទាំងអនុញ្ញាតឲ្យមន្ត្រីច្បាប់ជាន់ខ្ពស់ដដែលនេះបន្តការប្រាស្រ័យទាក់ទងបែបនេះតទៅទៀត) ដោយរំលោភយ៉ាងច្បាស់ក្រឡែតដល់សិទ្ធិរបស់ភាគី[7]។

## ខ.បណ្តឹងសារទុក្ខនេះអាចទទួលយកបានស្របតាមវិធាន២១ នៃវិធានផ្ទៃក្នុង

៥. សហព្រះរាជអាជ្ញាបានលើកក្នុងកថាខណ្ឌទី៩ ថាអង្គជំនុំជម្រះតុលាការកំពូលបានសម្រេចកាលពីលើកមុនថា យុត្តាធិការរបស់ខ្លួនលើបណ្តឹងសារទុក្ខភ្លាមៗត្រូវបានកម្រិតត្រឹមតែលើបញ្ហានានាដូចដែលមានចែងក្នុងវិធាន១០៤(៤) នៃវិធានផ្ទៃក្នុង។ នៅក្នុងសេចក្តីសម្រេចពីរដែលសហព្រះរាជអាជ្ញាបានដកស្រង់ អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងថាវិធាន១០៤(៤) នៃវិធានផ្ទៃក្នុង គឺមានកម្រិត ។ អង្គជំនុំជម្រះតុលាការកំពូលមិនបានពិចារណាថាតើបណ្តឹងសារទុក្ខដែលកំពុងមានបញ្ហានេះ នឹងអាចទទួលយកបានស្របតាមវិធាន២១នៃវិធានផ្ទៃក្នុងឬយ៉ាងណាទេ ព្រោះខ្លួនមិនត្រូវបានស្នើសុំឲ្យធ្វើដូច្នេះឡើយ ។ បណ្តឹងសារទុក្ខអាចទទួលយកបានស្របតាមវិធាន ២១ តែឯកឯងបានក្នុងករណីចាំបាច់ ដើម្បីការពារសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ។ អង្គបុរេជំនុំជម្រះទទួលស្គាល់ករណីនេះដោយបកស្រាយវិធាន ៧៤(៣) យ៉ាងទូលំទូលាយ ដើម្បីទទួលយកបណ្តឹងឧទ្ធរណ៍ដែលអាចមិនស្ថិតនៅយ៉ាងច្បាស់ក្នុងបញ្ជីទូលំទូលាយនៃសេចក្តីសម្រេច និងដីកានានាដែលអាចប្តឹងឧទ្ធរណ៍បាន[8] និងដោយទទួលយកបណ្តឹងឧទ្ធរណ៍ដោយផ្ទាល់តាមវិធាន២១[9] ។ ការបកស្រាយនេះនៅតែមានសុពលភាព ហើយដូច

---

[7] សូមមើលបណ្តឹងសារទុក្ខ, កថាខណ្ឌទី៩, ២២ ដល់ ២៩។

[8] សូមមើល ឧទាហរណ៍, សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងសាលដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធសំណើសុំអនុញ្ញាតថតសម្លេង/រូបភាពវីដេអូ នៃការជួបជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង, កថាខណ្ឌទី១៨។

[9] *សូមមើល* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតបដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន៦៦ និងសេចក្តីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី, កថាខណ្ឌទី១៣។

ដែលបានលើកឡើងដោយមេធាវីការពារក្តី[10] ការបកស្រាយបែបនេះគួរតែរក្សាទុក និងអនុវត្តឲ្យបានសមស្របដោយអង្គជំនុំជម្រះតុលាការកំពូល។

៦. នៅកថាខណ្ឌទី១០ សហព្រះរាជអាជ្ញាលើកឡើងថា អង្គបុរេជំនុំជម្រះពឹងផ្អែកលើវិធាន ២១ ដើម្បីបកស្រាយយ៉ាងទូលំទូលាយអំពីសិទ្ធិប្តឹងសារទុក្ខនៅដំណាក់កាលសវនាការមុនអង្គសេចក្តី ដោយហេតុថាបើពុំដូច្នេះទេ ជនជាប់ចោទនឹងមិនមានឱកាសប្តឹងសារទុក្ខឡើយ ។ នៅក្នុងករណីបច្ចុប្បន្ននេះ គេមិនចាំបាច់ធ្វើការដោះស្រាយតាមវិធាន ២១ ដោយសារសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការកាត់ក្តីដោយយុត្តិធម៌ ត្រូវបានការពារយ៉ាងគ្រប់គ្រាន់ដោយបទប្បញ្ញត្តិស្តីពីសិទ្ធិក្នុងការប្តឹងសារទុក្ខប្រឆាំងនឹងសេចក្តីសម្រេច ដែលរងការជំទាស់នៅដំណាក់កាលចុងក្រោយនៃកិច្ចដំណើរការនីតិវិធី ។ តាមពិតនេះជាមូលហេតុយ៉ាងច្បាស់ក្រឡែតថា តើហេតុអ្វីបានជាត្រូវអនុវត្តវិធាន ២១ ដើម្បីឲ្យបណ្តឹងសារទុក្ខនេះអាចទទួលយកបានភ្លាម ។ វិធាន១០៤ នៃវិធានផ្ទៃក្នុងមិនបានផ្តល់ការការពារអ្វីឡើយដល់លោក អៀង សារី ឡើយប្រសិនបើបណ្តឹងសារទុក្ខនេះមិនត្រូវបានទទួលយកភ្លាមទេនោះ ។ សិទ្ធិរបស់លោក អៀង សារី នឹងមិនត្រូវបានការពារឡើយ ។ លោក អៀង សារី នឹងមិនទទួលបានសំណាងអ្វីឡើយប្រសិនបើគាត់មិនអាចប្តឹងសារទុក្ខប្រឆាំងនឹងសេចក្តីសម្រេចដែលរងការជំទាស់នេះបានរហូតដល់ដំណាក់កាលចុងក្រោយនៃដំណើរការនីតិវិធី ។ ដល់ពេលនោះវានឹងហួសពេលទៅហើយដើម្បីកែតម្រូវទង្វើរបស់អង្គជំនុំជម្រះសាលាដំបូង ។ តាមពិតទៅវាស្ទើរតែមិនអាចកំណត់បានថា តើក្នុងស្ថានភាពណាមួយដែលអង្គជំនុំជម្រះសាលាដំបូងបានធ្វើការប្រាស្រ័យទាក់ទងរវាងភាគីតែម្ខាង នេះមិនទាន់គិតដល់ការកំណត់ពីរបៀបដែលលោក អៀង សារី រងការផលប៉ះពាល់ដោយការប្រាស្រ័យទាក់ទងគ្នាបែបនេះផង ឬមិនថាតើ លោក អៀង សារី នឹងត្រូវបានគេជួសជុលការខូចខាតតាមរបៀបណាចំពោះផលប៉ះពាល់បែបនេះ ។ ការប្រាស្រ័យទាក់ទង*រវាងភាគីតែម្ខាង* ធ្វើឲ្យប៉ះពាល់ដល់សុចរិតភាពនៃការជំនុំជម្រះក្តី ។ ដំណោះស្រាយដែលសមរម្យតែមួយគត់ គឺអាចជាការជំនុំជម្រះក្តីថ្មីមួយទៀតដែលប្រហែលជាមិនអាចកើតឡើងបានឡើ បើពិចារណាទៅលើពេលវេលា និងការចំណាយដែលពាក់ព័ន្ធ។ ដូចដែលបានពន្យល់ក្នុងបណ្តឹងសារទុក្ខនេះ មាត្រា២(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែល

[10] បណ្តឹងសារទុក្ខ, កថាខណ្ឌទី៤, ១១។

អង្គជំនុំជម្រះនៅ អវតក ត្រូវតែគោរព និងប្រកាន់ភ្ជាប់ស្របតាមរដ្ឋធម្មនុញ្ញ[11] តម្រូវថាលោក អៀង សារី ត្រូវតែទទួលបានដំណោះស្រាយ *ប្រកបដោយប្រសិទ្ធិភាព* ។ អង្គជំនុំជម្រះតុលាការកំពូលគួរតែយល់ឃើញថាបណ្តឹងសារទុក្ខនេះថាអាចទទួលយកបានភ្លាមដើម្បីផ្តល់ឲ្យលោក អៀង សារី នូវដំណោះ ស្រាយមួយប្រកបដោយប្រសិទ្ធិភាពចំពោះផលប៉ះពាល់ដែលលោកបានទទួលរង និងនៅតែបន្តទទួលរងទៀតដោយសារតែទង្វើរបស់អង្គជំនុំជម្រះសាលាដំបូង ។

**អាស្រ័យហេតុនេះ** សម្រាប់មូលហេតុដូចដែលបានបញ្ជាក់ក្នុងចម្លើយតបនេះ និងដែលត្រូវបានលើកឡើងយ៉ាងពេញលេញជាងនេះទៀតក្នុងបណ្តឹងសារទុក្ខ អង្គជំនុំជម្រះតុលាការកំពូលគួរតែយល់ឃើញថាបណ្តឹងសារទុក្ខរបស់លោក អៀង សារី ថាអាចទទួលយកបាន និងទទួលយកដំណោះស្រាយដែលបានលើកឡើងក្នុងចម្លើយតបនេះ។

_______________ _______________

អាង ឧត្តម Michael G. KARNAVAS

សហមេធាវីការពារក្តី អៀង សារី

ចុះហត្ថលេខា នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី **៧** ខែ **កុម្ភៈ ឆ្នាំ ២០១២**

[11] សូមមើលមាត្រា៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ ដែលបានធ្វើវិសោធនកម្មក្នុងឆ្នាំ១៩៩៩ ចែងថា ព្រះរាជាណាចក្រកម្ពុជាទទួលយក និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ, សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។